កម្រងសំណួររបស់អ្នកដាក់ពាក្យ (អំពីប្រវត្តិសាស្ត្រ និង រដ្ឋាភិបាល) សម្រាប់ការប្រលងចូលសញ្ជាតិ រដ្ឋាភិបាលសហរដ្ឋអាមេរិក

1. **តើអ្វីជា សិទ្ធិមួយ ឬ សេរីភាព ដែលកើតចេញពី ការធ្វើវិសោធនកម្មលើកទីមួយ?***
   - *ការបញ្ចេញមតិ*
   - *សាសនា*
   - *ការជួបប្រជុំ*
   - *សារព័ត៌មាន*
   - *ការដាក់ញត្តិទៅរដ្ឋាភិបាល*

2. **តើសហរដ្ឋអាមេរិកប្រកាន់នូវប្រព័ន្ធសេដ្ឋកិច្ចអ្វី?***
   - *សេដ្ឋកិច្ចមូលធននិយម*
   - *សេដ្ឋកិច្ចទីផ្សារ*

3. **ប្រាប់ឈ្មោះអំណាចឬ ផ្នែកមួយនៃការគ្រប់គ្រងរដ្ឋ***
   - *សភា*
   - *អំណាចនីតិបញ្ញត្តិ*
   - *ប្រធានាធិបតី*
   - *អំណាចនីតិប្រតិបត្តិ*
   - *តុលាការ*
   - *អំណាចតុលាការ*

4. **តើអំណាចទាំង ពីរ នៃ សភាសហរដ្ឋអាមេរិកមានអ្វីខ្លះ?***
   - *ព្រឹទ្ធសភា និង រដ្ឋសភា (សភាជាន់ទាប)*

5. **តើព្រឹទ្ធសមាជិកម្នាក់ប្រចាំរដ្ឋរបស់អ្នកជាអ្នកណា?***
   - *ចម្លើយនឹងខុសគ្នា[ប្រជាជននៅសង្កាត់កូឡុំប៊ីColumbia និង ប្រជាជននៅក្នុងសហរដ្ឋអាមេរិកគួរឆ្លើយថា D.C.(ឬ ទីកន្លែងដែលអ្នកដាក់ពាក្យរស់នៅ) មិនមានព្រឹទ្ធសមាជិកអាមេរិកទេ]*

6. **យើងបោះឆ្នោតជ្រើសរើសប្រធានាធិបតីនៅខែណា?***

- *ខែវិច្ឆិកា*

7. **តើប្រធានាធិបតីរបស់សហរដ្ឋអាមេរិកសព្វថ្ងៃនេះឈ្មោះអ្វី?***
   - *Donald J.Trump*
   - *DonaldTrump*
   - *Trump*

8. **តើរដ្ឋធានីនៃរដ្ឋរបស់អ្នកឈ្មោះអ្វី?***
   - *ចម្លើយនឹងខុសគ្នា [ប្រជាពលរដ្ឋនៅសង្កាត់កូឡុំប៊ីគួរឆ្លើយថាD.C. មិនមែនជារដ្ឋ និង មិនមានរដ្ឋធានីទេ ។ ប្រជាពលរដ្ឋនៅសហរដ្ឋអាមេរិក គួរដាក់ឈ្មោះរដ្ឋធានីតាមទីកន្លែងរបស់ខ្លួន]*

9. **តើគណបក្សនយោបាយធំពីរនៅសហរដ្ឋអាមេរិកមានអ្វីខ្លះ?***
   - *គណបក្សសាធារណរដ្ឋ និង គណបក្សប្រជាធិបតេយ្យ*

10. **តើអ្វីជាកាតព្វកិច្ច<u>មួយ</u> ដែលមានសម្រាប់តែពលរដ្ឋអាមេរិកកាំងប៉ុណ្ណោះ?***
    - *ចូលបម្រើក្នុងអង្គវិនិច្ឆ័យ*
    - *ចូលរួមបោះឆ្នោតថ្នាក់ជាតិ*

11. **តើប្រជាពលរដ្ឋត្រូវមានអាយុប៉ុន្មានដើម្បីមានសិទ្ធិបោះឆ្នោតជ្រើសរើសប្រធានាធិបតី?***
    - *ដប់ប្រាំបី(18) ឆ្នាំ ឡើង*

12. **តើថ្ងៃណាជាថ្ងៃចុងក្រោយដែលអ្នកអាចផ្ញើឯកសារពន្ធលើប្រាក់ចំណូល?***
    - *ថ្ងៃទី 15 ខែមេសា*

13. **តើប្រធានាធិបតីដំបូងគេបង្អស់ជាអ្នកណា?***
    - *(George)Washington*

14. **មានរឿងសំខាន់មួយដែល Abraham Lincolnបានធ្វើ តើជារឿងអ្វី?***
    - *រំដោះទាសករ(លិខិតប្រកាសស្តីពីការលុបចោលទាសភាព)*
    - *ជួយ(ឬ រក្សាទុក)សហជីព*
    - *ដឹកនាំសហរដ្ឋអាមេរិក ក្នុងសម័យសង្គ្រាមស៊ីវិល*

15. **ប្រាប់ឈ្មោះសង្គ្រាម មួយ ដែលកើតនៅសហរដ្ឋអាមេរិកក្នុងទសវត្សរ៍ឆ្នាំ 1900s.***
    - *សង្គ្រាមលោកលើកទីI*
    - *សង្គ្រាមលោកលើកទី II*
    - *សង្គ្រាមកូរ៉េ*
    - *សង្គ្រាមវៀតណាម*
    - *សង្គ្រាមឈូងសមុទ្រ(ពែក)*

16. **តើលោក MartinLutherKing,Jr.បានធ្វើអ្វីខ្លះ?***
    - *តស៊ូដើម្បីសិទ្ធិពលរដ្ឋ*
    - *ធ្វើការដើម្បីសមភាពសម្រាប់ជនជាតិអាមេរិកាំងគ្រប់រូប*

17. **តើរដ្ឋធានីរបស់សហរដ្ឋអាមេរិកឈ្មោះអ្វី?***
    - *រដ្ឋធានី វ៉ាស៊ីនតោនឌីស៊ី Washington,D.C.*

18. **តើរូបសំណាកសេរីភាពស្ថិតនៅទីកន្លែងណា?***
    - *ញូយក (ហាប៊ីរ)*
    - *កោះសេរីភាព LibertyIsland*

    *[ចម្លើយក៏អាចត្រូវផងដែរគឺ រដ្ឋញូជេស៊ី NewJersey ជិតទីក្រុងញ៉ូយ៉ក NewYork City និង នៅ(ទន្លេ)ហាត់សុនHudson]*

19. **ហេតុអ្វីបានជាទង់ជាតិអាមេរិកមាន50ផ្កាយ?***
    - *ដោយសារតែផ្កាយមួយគឺសម្រាប់រដ្ឋមួយ*
    - *ដោយសារតែផ្កាយមួយតំណាងឱ្យរដ្ឋមួយ*
    - *ដោយសារតែមានរដ្ឋចំនួន 50*

20. **តើយើងប្រារព្ធពិធីបុណ្យឯករាជ្យជាតិនៅថ្ងៃណា?***
    - *ថ្ងៃទី 4 ខែកក្កដា*